ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីស្លាប់បុរសជនជាតិខ្មែរអាយុ ៥៨ឆ្នាំ ដោយសារ ជំងឺកូវីដ-១៩

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា យោងតាមរបាយការណ៍ពីមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ បានឱ្យដឹងថា បុរសជនជាតិខ្មែរអាយុ ៥៨ឆ្នាំ ដែលរស់នៅភូមិបន្ទាយរកា ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ បានស្លាប់បាត់បង់ជីវិតដោយសារជំងឺកូវីដ-១៩ នាថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ០៩ :២០នាទី ព្រឹក។

កាលពីព្រឹកថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០២១ នៅវេលាម៉ោង ៨:៣០នាទី ព្រឹក បុរសរូបនេះ បានចូលមកក្នុងមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ ដោយមានអាការៈពេគហត់ដង្ហក់ពិបាកដកដង្ហើម។ ពេលមកដល់មន្ទីរពេទ្យ ដោយឃើញមានសញ្ញាសង្ស័យពីជំងឺកូវីដ-១៩ គ្រូពេទ្យផ្នែកសង្គ្រោះបន្ទាន់ក៏បានដាក់បុរសរូបនេះក្នុងបន្ទប់ដាច់ដោយឡែកហើយក៏រៀបចំស្លៀកពាក់សម្លៀកបំពាក់ការពារវីរុសកូវីដ-១៩ ដើម្បីចូលទៅសង្គ្រោះ។ ដោយសារអ្នកជំងឺមានសភាពធ្ងន់ធ្ងរពេកពុំអាចសង្គ្រោះបាន អ្នកជំងឺក៏បានស្លាប់បាត់បង់ជីវិត នៅវេលាម៉ោងប្រមាណ ៩:២០នាទី ព្រឹក។ ដោយមានសញ្ញាសង្ស័យជំងឺកូវីដ-១៩ គ្រូពេទ្យក៏បានយកសំណាកដើម្បីពិនិត្យរកមើលវីរុសកូវីដ-១៩។ នៅវេលាម៉ោង ០៥:២០នាទី ល្ងាចថ្ងៃដដែល ដោយវិទ្យាស្ថានជាតិសុខភាពសាធារណៈបានបញ្ជាក់លទ្ធផលវិជ្ជមានជំងឺកូវីដ-១៩។

**ការសន្និដ្ឋានរបស់ក្រុមគ្រូពេទ្យ៖** បុរសជនជាតិខ្មែរអាយុ ៥៨ឆ្នាំ ខាងលើនេះ បានស្លាប់បាត់បង់ជីវិតដោយសារមានវិបត្តិផ្លូវដកដង្ហើមធ្ងន់ធ្ងរបណ្តាលមកពីជំងឺកូវីដ-១៩។

ក្រសួងសុខាភិបាល សូមចូលរួមចំណែកសោកស្តាយជាពន់ពេក និងសូមចូលរួមមរណទុក្ខយ៉ាងក្រៀមក្រំជាទីបំផុតជាមួយក្រុមគ្រួសារសព។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៣កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**
រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ទីស្តីការក្រសួងសុខាភិបាលដីឡូតិ៍លេខ៨០ វិថីសម្ដេចប៉ែន នុត(២៨៩)ភ្នំពេញ ទូរស័ព្ទលេខ-ទូរសារ:(៨៥៥-២៣)៨៥៥ ៩៧០/៨៨៤ ៩០៩